# សុន្ទរកថា

## ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
## ក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិ លើកទី២ ស្តីពីការរៀបចំ«យុទ្ធសាស្រ្ត និងផែនការ សកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣»

**រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦**

*ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកសារព័ត៌មាន*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពីធីបើកសិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពី«យុទ្ធសាស្រ្តនិងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣» នាពេលនេះ។

ក្នុងនាមក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងសិក្ខាសាលាថ្ងៃនេះ ដែលញ៉ាំងឱ្យកិច្ចពិភាក្សាពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្រ្តនេះប្រព្រឹត្តទៅប្រកបដោយភាពផុលផុស ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈមជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថានមហាអនុតំបន់មេគង្គ ដែលបានជួយឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា បច្ចេកទេស និងធនធានមនុស្សដល់ដំណើរការរៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្រ្តដ៏មានសារៈសំខាន់នេះ ។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ «ក្រុមការងារចំពោះកិច្ច» ដែលមានភារកិច្ចទទួលបន្ទុកសម្របសម្រួល និងដឹកនាំកិច្ចប្រជុំបច្ចេកទេស និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្រ្តនិងផែនការសកម្មភាពនេះ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ចាប់តាំង ពីពេល ដែលសេចក្តីព្រាងឯកសារនេះត្រូវបានដំណើរការក្នុងខែកញ្ញា ឆ្នាំ២០១៥មក។

ការជួបជុំគ្នាថ្ងៃនេះ មិនត្រឹមតែជាសក្ខីភាពបញ្ជាក់នូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលចំពោះការរៀបចំឱ្យមានយុទ្ធសាស្រ្តនិងផែនការបរិស្ថានជាតិ ដើម្បីបញ្ចូលបញ្ហាបរិស្ថានទៅក្នុងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការវិនិយោគទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប៉ុណ្ណោះទ ប៉ុន្តែថែមទាំង

ជាកញ្ចក់ឆ្លុះឱ្យឃើញនូវសមានចិត្តចូលរួមគាំទ្រពីគ្រប់មជ្ឈដ្ឋាន ក្នុងដំណើរការរៀបចំឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ ដើម្បីបម្រើឱ្យឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូលជាទីមេត្រី!***

បរិស្ថាន និងធនធានធម្មជាតិ ដូចជា ដី ទឹក ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេង និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូង ព្រៃ និងផលិតផលព្រៃឈើ សត្វព្រៃ ធនធានមច្ឆជាតិ និង សត្វក្នុងទឹក ជាគ្រឹះនៃសេដ្ឋកិច្ច សង្គម វប្បធម៌ជាតិ និងសុខុមាលភាពមនុស្សម្នាក់ៗ និងមានតម្លៃសោភ័ណ្ឌភាព និងតម្លៃមិនអាចកាត់ថ្លៃបាន។ សម្រាប់កម្ពុជាយើង ដើម្បីបន្តល្បឿននៃការអភិវឌ្ឍទៅមុខទៀត យើងចាំបាច់បន្តធ្វើការ ផ្លាស់ប្តូររបៀបប្រើប្រាស់ធនធាន បង្កើនប្រសិទ្ធផល និងផលិតកម្មពី ការប្រើប្រាស់ធនធាន កាត់បន្ថយ សំណល់ និងការបំពុលទាំងឡាយ។ ការការពារបរិស្ថាន និងធនធានធម្មជាតិ គឺជាកិច្ចការងារដ៏សំខាន់សម្រាប់ កម្ពុជា ព្រោះចីរភាពរបស់វា គឺជាប្រភពចំបងនៃការរីកចម្រើននិង ការអភិវឌ្ឍ ក្នុងរយៈពេលវែង។

យើងបានឃើញថា ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចលឿនជាងសមត្ថភាពស្ថាប័ន និងច្បាប់សម្រាប់ការការពារបរិស្ថាន និងលឿនជាងការប្រើប្រាស់បច្ចេកវិទ្យា ដែលមានមេត្រីភាពបរិស្ថាន និងឥរិយាបទរបស់មនុស្ស ដែលស្រឡាញ់បរិស្ថាន។ យើងត្រូវដោះស្រាយផងដែរ រវាងតម្លៃនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរយៈពេលវែង និងការទទួលផលសេដ្ឋកិច្ចរយៈពេលខ្លី។ «ទង្វើតាមទម្លាប់ចាស់» គឺមិនមែនជាជម្រើសដ៏ល្អសម្រាប់កម្ពុជាទេ សម្រាប់ឈានទៅរកសង្គមជាតិមួយដែលមានព័ណ៌បៃតង មានកាបូនទាប មានភាពធន់នឹងការប្រែប្រួលអាកាសធាតុ សមភាព និរន្តរភាព និងប្រកបដោយចំណេះដឹង។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការជាច្រើនរួចមកហើយ ដើម្បីកាត់បន្ថយសម្ពាធទៅលើ និងការបាត់បង់បរិស្ថាន និងធនធានធម្មជាតិ តាមរយៈការរៀបចំបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិ និងជីវៈចម្រុះ ការកែទម្រង់ស្ថាប័ន ការពង្រឹងការអនុវត្តច្បាប់ទប់ទល់នឹងអំពើអវិជ្ជមាន និងអសកម្មក្នុងការគ្រប់គ្រងសម្បទានសេដ្ឋកិច្ចដីធ្លី និងទប់ទល់នឹងការកាប់ព្រៃ និងការនាំឈើចេញដោយខុសច្បាប់។ យើងក៏បានពង្រឹង និងការពារសិទ្ធិកាន់កាប់ដីធ្លី និងប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ បានបញ្ជាក់យ៉ាងច្បាស់ពីបេសកកម្ម និងការបន្តប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍន៍ដោយចីរភាព និងកាត់បន្ថយភាពក្រីក្រ ដែលជាការឆ្លើយតបទៅនឹងសេចក្តីប្រាថ្នារបស់ប្រជាជន និងបរិបទថ្មីនៃការអភិវឌ្ឍជាតិ និងអន្តរជាតិ។ រាជរដ្ឋាភិបាលបានចាត់ទុកនិរន្តរភាពបរិស្ថានជាកត្តា ឬជាបុរេល័ក្ខខ័ណ្ឌមួយ ក្នុងការសម្រេចឱ្យបាន គោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា។ ការប្តេជ្ញាចិត្តក្នុងការបញ្ជ្រាបនិរន្តរភាពបរិស្ថាន ការអភិវឌ្ឍដោយមានតុល្យភាព និងការចូលរួម ការគិតគូរអំពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ បានស្តែងឡើងបន្ថែមទៀត តាមរយៈការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងឆ្នាំ២០១៥ ដោយប្របាច់បញ្ចូលគ្នាគណៈកម្មាធិការជាតិស្តីពី កាប្រែប្រួលអាកាសធាតុ និងក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍបៃតង។

ដោយមើលឃើញពីភាពចាំបាច់ ក្នុងការឆ្លើយតបទៅនឹងដំណើរវិវត្តន៍ និងនិន្នាការរីកចម្រើននៃសេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា វិទ្យាសាស្ត្រ ក៏ដូចជា ការប្រឈមនឹងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលបានបង្កើត «ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព» ដែលមានសមាសភាពចូលរួមមកពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ដើម្បីសម្របសម្រួលការងាររៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ក្នុងវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

យើងចាំបាច់ខិតខំប្រឹងប្រែងរួមគ្នាបន្ថែមទៀត ដើម្បីគ្រប់គ្រងដោយមានប្រសិទ្ធភាពទៅលើកត្តាជម្រុញទាំងឡាយ និងផលប៉ះពាល់ទៅលើមូលធនធម្មជាតិ ដោយផ្តោតជាពិសេស លើការដោះស្រាយធនធានហិរញ្ញវត្ថុ និងសមត្ថភាព លើកកម្ពស់ការយល់ដឹងអំពីតម្លៃ និងភាពងាយរងគ្រោះនៃមូលធនធម្មជាតិ ដែលចាំបាច់សម្រាប់ការរីកចម្រើនដោយចីរភាព និងសុខុមាលភាពសង្គមជាតិយើង។

ដើម្បីសម្រេចបានជោគជ័យក្នុងបេសកកម្មរបស់ខ្លួនជូនរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការកសាងសង្គមមានការអភិវឌ្ឍដោយចីរភាពនិងបរិស្ថានល្អស្អាត និងភាពសុខដុមរមនា សម្រាប់ប្រជាជនគ្រប់ជំនាន់ ក្រសួងបរិស្ថាន បានចាប់ផ្តើមពីការពង្រឹងសមត្ថភាពស្ថាប័នជាមុន តាមរយៈការធ្វើទំនើបកម្មស្ថាប័ន ដែលរួមមាន៖ ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ល។ ជាងនេះទៅទៀត ដោយមានការអនុញ្ញាត ជាគោលការណ៍ពីរាជរដ្ឋាភិបាល ក្រសួងក៏បានចាប់ផ្តើមដឹកនាំដំណើរការរៀបចំកែសម្រួល និងកសាងក្របខ័ណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសំខាន់ៗ សម្រាប់វិស័យបរិស្ថានទាំងមូលផងដែរ។

រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តវិធីសាស្ត្រពីរស្របគ្នាក្នុងពេលតែមួយ ក្នុងការរៀបចំក្រមបរិស្ថាន និងរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការថយចុះគុណភាពបរិស្ថាន និងធនធានធម្មជាតិ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងដើម្បីទទួលផលប្រយោជន៍ពីការអភិវឌ្ឍបៃតង។

កិច្ចសហការ និងសមាហរណកម្មឆ្លងវិស័យ ដូចជាការផ្ទេរការទទួលខុសត្រូវរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រង អភិរក្ស និងការពារ តំបន់ការពារ ដីសម្បទានសេដ្ឋកិច្ច និងតំបន់ព្រៃដ៏ទៃទៀត និងកិច្ចសហការអន្តរក្រសួងរវាងក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ និងនគរបាលជាតិ លើការងារគ្រប់គ្រងតំបន់ឆ្នេរ គឺជាសមិទ្ធផលគួរឱ្យកត់សម្គាល់ ដែលត្រូវបន្តពង្រឹង និងពង្រីកបន្តទៀត តាមរយៈការបង្កើតស្ថានភាពអនុគ្រោះល្អប្រសើរថែមទៀត ដូចជា ក្រមបរិស្ថាន និងការផ្តល់ធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយចីរភាព និងបច្ចេកវិទ្យា និងឧបករណ៍វិទ្យាសាស្ត្រសម្រាប់គាំទ្រដល់ការសម្រេចចិត្ត និងការត្រួតពិនិត្យការរាយការណ៍។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូលជាទីមេត្រី!***

សកម្មភាពទាំងនេះគឺ ជាការឆ្លើយតបជាយុទ្ធសាស្ត្រទៅនឹងភាពចាំបាច់ក្នុងការធ្វើទំនើបកម្ម នៃការគ្រប់គ្រង និងអភិបាលកិច្ចបរិស្ថាន និងធនធានធម្មជាតិ ដើម្បីបោះជំហានឆ្ពោះទៅដល់ការគ្រប់គ្រង

ដែល បានគិតគូរគ្រប់ជ្រុងជ្រោយ លើប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ។ ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាព បរិស្ថានជាតិ គឺស្របតាមមាត្រាទី៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ និងស្របតាម គោលនយោបាយ និង ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។

ការងារបរិស្ថានជាកិច្ចការដែលមានលក្ខណៈសកល និងពហុវិស័យ ហើយដែលទាមទារឱ្យបណ្តា រដ្ឋាភិបាល និងប្រជាជាតិទាំងអស់ នៅលើសកលលោក បន្តខិតខំចូលរួមចំណែក ថែរក្សាការពារឱ្យបាន កាន់តែខ្លាំងក្លាថែមទៀត ដើម្បីធានាឱ្យបាននូវការរស់នៅដោយចីរភាព និងសុវត្ថិភាព នៃភពផែនដី ទាំងមូល។

ដោយសារចរិកលក្ខណៈពហុវិស័យនៃការគ្រប់គ្រងបរិស្ថាន យុទ្ធសាស្ត្រ និងផែនការសកម្មភាព បរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣ មិនមែនជាយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់តែ ក្រសួង បរិស្ថានមួយនោះទេ ប៉ុន្តែជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ក្រសួង ស្ថាប័នជាតិទាំងអស់ ព្រមទាំងសម្រាប់វិស័យឯកជន សង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍នានាផងដែរ ដើម្បីដាក់បញ្ចូល ការគិត គូពីបរិស្ថានទៅក្នុងគោលនយោបាយ សេដកិច្ច និងការវិនិយោគនៅថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ។

ក្នុងន័យនេះ ខ្ញុំក៏សូមទាញការចាប់អារម្មណ៍ពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី នូវ ចំណុចសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងប្រភពនិងគោលការណ៍ជាមូលដ្ឋាន ដែលត្រូវបានប្រើប្រាស់ សម្រាប់ ការរៀបចំកសាងឯកសារនេះ។ ជារួម ក្រុមការងារយើងបានគិតគូរអំពីគោលដៅអាទិភាពមួយចំនួន ដែល ជាមូលដ្ឋានគ្រឹះ សម្រាប់កសាងយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ដោយអនុលោមតាម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធនធានធម្មជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ ២០១៤-២០១៨។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ បានរៀបចំឡើងស្របទៅតាមគោលការណ៍ណែនាំ ស្តីអំពី ការរៀបចំតាក់តែងគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ បានបូកបញ្ចូល រាល់ធាតុចូលសំខាន់ៗនានា ដែលទទួលបានពីកិច្ចប្រជុំការងារ និងការពិគ្រោះយោបល់ច្រើន លើកច្រើនសារ ជាមួយក្រសួងស្ថានប័នពាក់ព័ន្ធ ដៃគូរអភិវឌ្ឍន៍ សង្គមស៊ីវិល និងតំណាង ជាន់ខ្ពស់របស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញខេត្ត ដើម្បីធ្វើយ៉ាងណាឱ្យយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិនេះ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ត្រូវឆ្លើយតបទៅ នឹងសេចក្តី ត្រូវការរបស់សង្គមជាតិ និងសមស្រប និងបំពេញបន្ថែមទៅនឹង បណ្តាកម្មវិធីយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធនានា។ យុទ្ធសាស្ត្រ និងផែនការសកម្មភាព បរិស្ថានជាតិក៏ ត្រូវគិតគូរផងដែរអំពីកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌកិច្ចព្រម ព្រៀងបរិស្ថាន

ទ្វេភាគី និងពហុភាគីនានា នៅក្នុងវិស័យដូចជា ការប្រែប្រួលអាកាសធាតុ គោលដៅអភិវឌ្ឍន៍ដោយចីរភាព ជីវៈចម្រុះ និងជីវៈសុវត្ថិភាព តំបន់ដីសើម បេតិកភ័ណ្ឌធម្មជាតិ និងវប្បធម៌ ការអភិវឌ្ឍបៃតង ការគ្រប់គ្រងសំណល់ និងសារធាតុគ្រោះថ្នាក់ ការគ្រប់គ្រងសារជាតិពុលគីមីដែលមិនបំបែកខ្លួន ការការពារស្រទាប់អូហ្សូន ការបំពុលបរិស្ថាន និងធនធានធម្មជាតិ និងបរិស្ថាន សមុទ្រ និងលំហសមុទ្រ។ល។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ត្រូវដើតួនាទីជាផែនទីបង្ហាញផ្លូវ សម្រាប់រៀបចំផែនការដែលមានលក្ខណៈយុទ្ធសាស្ត្រ និងឆ្លងវិស័យ សម្រាប់ក្រុមប្រឹក្សា ជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងសមាជិកនានា ក្នុងការកៀរគរធនធាន ដើម្បីចូលរួម ចំណែកបន្ថែមទៀត ដល់ការអនុវត្តឱ្យបានសម្រេចនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូលជាទីមេត្រី!***

ខ្ញុំសូមចាត់ទុកសិក្ខាសាលាថ្ងៃនេះ ជាការប្រមូលផ្តុំនូវកម្លាំងនិងធនធានមនុស្សមកពីគ្រប់មជ្ឈដ្ឋាន ដើម្បីជំរុញឱ្យដំណើរការនៃការកសាងឯកសារ «យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣»នេះ ដើម្បីជា«**ត្រីវិស័យ**»តម្រង់ទិសដល់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយតម្រូវឱ្យយើងទាំងអស់គ្នាចេះប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសនិទានភាព តាមរយៈការគិតគូរឱ្យបានស៊ីជម្រៅនៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចបរិស្ថាន សំដៅធានាបាននូវតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ នឹងបន្តផ្តល់នូវកិច្ចសហការដ៏ល្អជាមួយក្រសួងបរិស្ថាន ក៏ដូចជាក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងការជំរុញឱ្យដំណើរការនៃការរៀបចំសេចក្តីព្រាងឯកសារនេះប្រព្រឹត្តទៅដោយរលូន និងសម្រេចបានលទ្ធផលជាផ្លែផ្កាជូនរាជរដ្ឋាភិបាល និងប្រជាជនជាទីស្រឡាញ់នៃយើង។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមស្នើឱ្យ«ក្រុមការងារចំពោះកិច្ច» សូមបន្តធ្វើការជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ ដោយធ្វើយ៉ាងណាឱ្យ ឯកសារនេះមានលក្ខណៈបត់បែន ដែលអាចអនុវត្តបាន និងមានតម្លៃគ្រប់កាលៈទេសៈ ហើយខ្ញុំក៏សូមឱ្យសមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូល មេត្តាចូលរួមចែករំលែកនូវបទពិសោធនិងគំនិតល្អៗ ដើម្បីឱ្យសិក្ខាសាលានេះ ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ តាមការគ្រោងទុក។

ខ្ញុំសូមយកឱកាសនេះអំពាវនាវដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាវាគ្មិននិងអ្នកចូលរួមទាំងអស់ សូមមេត្តាយកចិត្តទុកដាក់ពិចារណាលើមូលដ្ឋានសំខាន់ៗមួយចំនួនទៀត ដូចជា ការកំណត់បញ្ហាអាទិភាព កត្តាសមត្ថភាព កត្តាលទ្ធភាព និងតម្រូវការ របស់ប្រជាជន ក៏ដូចជា កត្តាវប្បធម៌ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត «យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣» នៅក្នុងសង្គមជាតិរបស់យើង។ គោលគំនិតសំខាន់ក្នុងចំណុចនេះគឺ ធ្វើយ៉ាងណាឱ្យទាំងអស់គ្នាយល់ថា ស្នាដៃដែលប្រសូតចេញមកនេះ គឺជាស្នាដៃរបស់យើងទាំងអស់គ្នានិងក៏ជាស្នាដៃដើម្បីបុព្វហេតុបរិស្ថាន។

ជារួម ខ្ញុំចង់ឃើញគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដើរលើផ្លូវតែមួយ ក្រោមដំបូលនៃស្មារតីម្ចាស់ការ មោទនភាពជាតិ និងការឯកភាពជាតិជាធ្លុងមួយ។ ខ្ញុំយល់ថា មានតែភាពជឿជាក់ និងភាពម្ចាស់ការលើខ្លួនឯងទេ ដែលអាចធ្វើឱ្យយើងរួមគ្នាជាកម្លាំងពិត សម្រាប់ជំរុញការអភិវឌ្ឍលើគ្រប់វិស័យ ប្រកបដោយនិរន្តរភាព។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានជួយគាំទ្រដល់ដំណើររៀបចំឯកសារជាតិដ៏មានសារៈសំខាន់នេះ ហើយខ្ញុំក៏សូមអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ បន្តជួយជំរុញការងារនេះ ឱ្យសម្រេចបានជោគជ័យ តាមផែនការកំណត់។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រកបដោយពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ និងសូមមានសុភមង្គលគ្រប់ក្រុមគ្រួសារ។

*ខ្ញុំសូមប្រកាសបើកសិក្ខាសាលាស្តីពី យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣ ចាប់ពីពេលនេះតទៅ!*

*សូមអរគុណ!*